**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
លេខ :................៧៧១..........ក.ប/ស.ជិ.ណ

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ២០១៥

# សេចក្តីជូនដំណឹង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណៈជន ជាពិសេសសិស្សានុសិស្ស ដែលទើបប្រឡងបញ្ចប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៥ថ្មីៗនេះ និងឆ្នាំកន្លងមក សិស្សានុសិស្សដែលបានបញ្ចប់ការសិក្សាត្រឹមថ្នាក់ទី៩ អាណាព្យាបាល និងស្ថាប័នដែលពាក់ព័ន្ធទាំងអស់ មេត្តាជ្រាបថា ក្រសួងនឹងរៀបចំវេទិកាផ្សព្វផ្សាយអំពីវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៅសាលមហោស្រពកោះពេជ្រ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៥ ម៉ោង ៧:៣០នាទីព្រឹកខាងមុខនេះ។ វេទិការនេះគឺមានសារៈសំខាន់ណាស់សម្រាប់សិស្សានុសិស្សឲ្យបានយល់ដឹងពីជំនាញដែលទីផ្សារការងារត្រូវការបច្ចុប្បន្ន និងទៅអនាគត ដើម្បីជាមូលដ្ឋានគ្រឹះក្នុងការសម្រេចចិត្តជ្រើសរើសជំនាញមកសិក្សា។ លើសពីនេះទៅទៀត គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្រោមឱវាទក្រសួងនឹងធ្វើការណែនាំលើមុខជំនាញបច្ចេកទេសដែលខ្លួនកំពុងធ្វើការបណ្តុះបណ្តាល ហើយទទួលបានជោគជ័យនាពេលកន្លងមក។ គ្រឹះស្ថានទាំងនោះក៏នឹងទទួលចុះឈ្មោះស្នើសុំអាហារូបករណ៍របស់សិស្សានុសិស្សផងដែរ។

ព័ត៌មានបន្ថែមសូមធ្វើការទំនាក់ទំនងជាមួយនាយកដ្ឋានព័ត៌មានទីផ្សារការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានអាសយដ្ឋានអគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឬតាមរយៈលេខទូរស័ព្ទ: ០១២ ៣០៦ ៨៥៥/០១១ ៨៥៣ ៨១២/០១០ ៣០៦ ៨៥៥/ ០១២ ២២៣ ១៨៩ អ៊ីម៉ែល: thorng_samon@yahoo.com។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណៈជន សិស្សានុសិស្ស អាណាព្យាបាល និងស្ថាប័នដែលពាក់ព័ន្ធទាំងអស់មេត្តាជ្រាបជាព័ត៌មាន និងចូលរួមឲ្យបានច្រើនកុះករ។

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

<u>ចំម្លងជូន:</u>
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត និងអង្គភាពពាក់ព័ន្ធ
- គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរាជធានី-ខេត្ត

"ដើម្បីផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ